គណិតវិទ្យាថ្ងៃនេះ

MathtodaY

សៀវភៅគណិតវិទ្យាកម្រិតវិទ្យាល័យ

ភាពជាប់នៃអនុគមន៍

* សង្ខេបមេរៀននិងគន្លឹះដោះស្រាយសំខាន់ៗ
* លំហាត់ជ្រើសរើសអមដោយដំណោះស្រាយក្បោះក្បាយ
* លំហាត់ជ្រើសរើសសម្រាប់កិច្ចការផ្ទះ

សម្រាប់ថ្នាក់ទី១២ ថ្នាក់វិទ្យាសាស្ត្រពិតនិងថ្នាក់វិទ្យាសាស្ត្រសង្គម

អ្នករៀបរៀង លឹម ផល្គុន

2020

ស្របតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំយុវជននិងកីឡា

លំហាត់ទី២៦

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 0}\dfrac{1+x\sin x-\cos 2x}{\sin^2 x}$

ខ. $\lim\limits_{x\to 0}\dfrac{\sin 3x}{\sqrt{x+2}-\sqrt{2}}$

គ. $\lim\limits_{x\to 0}\dfrac{\sin^2 x}{\sqrt{1+x\sin x}-\cos x}$

ឃ. $\lim\limits_{x\to 0}\dfrac{\tan x-\sin x}{x^3}$

ង. $\lim\limits_{x\to 0}\dfrac{1+\sin x-\cos x}{1-\sin x-\cos x}$

ច. $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}$

ឆ. $\lim\limits_{x\to 0}\dfrac{1-\cos x.\cos 2x}{x^2}$

ជ. $\lim\limits_{x\to 0}\dfrac{1-\cos(1-\cos x)}{x^4}$

ឈ. $\lim\limits_{x\to 1}(1-x^2)\tan\dfrac{\pi x}{2}$

ញ. $\lim\limits_{x\to 1}\dfrac{\tan \pi x}{1-x}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to 0}\dfrac{1+x\sin x-\cos 2x}{\sin^2 x}$ រាងមិនកំណត់ $\dfrac{0}{0}$

$$=\lim_{x\to 0}\frac{x\sin x+2\sin^2 x}{\sin^2 x}=\lim_{x\to 0}\left(\frac{x}{\sin x}+2\right)=1+2=3$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1+x\sin x-\cos 2x}{\sin^2 x}=3$ ។

ខ. $\lim\limits_{x\to 0}\dfrac{\sin 3x}{\sqrt{x+2}-\sqrt{2}}$ រាងមិនកំណត់ $\dfrac{0}{0}$

$$=\lim_{x\to 0}\frac{\left(\sqrt{x+2}+\sqrt{2}\right)\sin 3x}{x+2-2}=\lim_{x\to 0}\left[\left(\sqrt{x+2}+\sqrt{2}\right)\frac{\sin 3x}{3x}\times 3\right]=6\sqrt{2}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{\sin^2 x}{\sqrt{1+x\sin x}-\cos x}$ រាង $\lim\limits_{x\to 0}\dfrac{\sin 3x}{\sqrt{x+2}-\sqrt{2}}=6\sqrt{2}$ ។

គ. $\lim\limits_{x\to 0}\dfrac{\sin^2 x}{\sqrt{1+x\sin x}-\cos x}$ រាងមិនកំណត់ $\dfrac{0}{0}$

$$= \lim_{x\to 0}\frac{\left(\sqrt{1+x\sin x}+\cos x\right)\sin^2 x}{1+x\sin x-\cos^2 x} = \lim_{x\to 0}\frac{\left(\sqrt{1+x\sin x}+\cos x\right)\sin^2 x}{x\sin x+\sin^2 x}$$

$$= \lim_{x\to 0}\frac{\left(\sqrt{1+x\sin x}+\cos x\right)\sin x}{x+\sin x} = \lim_{x\to 0}\frac{\left(\sqrt{1+x\sin x}+\cos x\right)\frac{\sin x}{x}}{1+\frac{\sin x}{x}} = \frac{2\times 1}{2} = 1$$

ដូចនេះ $\lim_{x\to 0}\frac{\sin^2 x}{\sqrt{1+x\sin x}-\cos x} = 1$ ។

ឃ. $\lim_{x\to 0}\frac{\tan x-\sin x}{x^3}$ រាងមិនកំណត់ $\frac{0}{0}$

តាមរូបមន្ត $\tan x = \frac{\sin x}{\cos x}$ ឬ $\sin x = \tan x\cos x$

$$= \lim_{x\to 0}\frac{\tan x-\tan x\cos x}{x^3}$$

$$= \lim_{x\to 0}\frac{\tan x(1-\cos x)}{x^3}$$

$$= \lim_{x\to 0}\frac{\tan x(1-\cos x)(1+\cos x)}{x^3(1+\cos x)}$$

$$= \lim_{x\to 0}\frac{\tan x(1-\cos^2 x)}{x^3(1+\cos x)}$$

$$= \lim_{x\to 0}\frac{\tan x}{x}\times\frac{\sin^2 x}{x^2}\times\frac{1}{1+\cos x} = 1\times 1\times\frac{1}{2} = \frac{1}{2}$$

ដូចនេះ $\lim_{x\to 0}\frac{\tan x-\sin x}{x^3} = \frac{1}{2}$ ។

ង. $\lim_{x\to 0}\frac{1+\sin x-\cos x}{1-\sin x-\cos x}$ រាងមិនកំណត់ $\frac{0}{0}$

$$= \lim_{x\to 0}\frac{\frac{1+\sin x-\cos x}{x}}{\frac{1-\sin x-\cos x}{x}} = \lim_{x\to 0}\frac{\frac{1-\cos x}{x}+\frac{\sin x}{x}}{\frac{1-\cos x}{x}-\frac{\sin x}{x}} = \frac{0+1}{0-1} = -1$$

ដូចនេះ: $\lim\limits_{x\to 0}\dfrac{1+\sin x-\cos x}{1-\sin x-\cos x}=-1$ ។

ប. $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}$ រាងមិនកំណត់ $\dfrac{0}{0}$

$$=\lim_{x\to 0}\frac{(1-\cos x)+\cos x(1-\sqrt{\cos 2x})}{x^2}$$

$$=\lim_{x\to 0}\frac{1-\cos x}{x^2}+\lim_{x\to 0}\frac{\cos x}{1+\sqrt{\cos 2x}}\frac{1-\cos 2x}{x^2}$$

$$=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{x^2}+\lim_{x\to 0}\frac{\cos x}{1+\sqrt{\cos 2x}}\frac{2\sin^2 x}{x^2}$$

$$=2\lim_{x\to 0}\frac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}\times\frac{1}{4}+2\lim_{x\to 0}\frac{\cos x}{1+\sqrt{\cos 2x}}\times\frac{\sin^2 x}{x^2}$$

$$=2\times\frac{1}{4}+2\times\frac{1}{2}=\frac{1}{2}+1=\frac{3}{2}$$

ដូចនេះ: $\lim\limits_{x\to 0}\dfrac{1-\cos x\sqrt{\cos 2x}}{x^2}=\dfrac{3}{2}$ ។

ផ. $\lim\limits_{x\to 0}\dfrac{1-\cos x\cos 2x}{x^2}$ រាងមិនកំណត់ $\dfrac{0}{0}$

$$=\lim_{x\to 0}\frac{(1-\cos x)+\cos x(1-\cos 2x)}{x^2}=\lim_{x\to 0}\frac{2\sin^2\frac{x}{2}+2\cos x\sin^2 x}{x^2}$$

$$=2\lim_{x\to 0}\frac{\sin^2\frac{x}{2}}{\left(\frac{x}{2}\right)^2}\times\frac{1}{4}+2\lim_{x\to 0}\left(\cos x\,\frac{\sin^2 x}{x^2}\right)=2\times\frac{1}{4}+2=\frac{1}{2}+2=\frac{5}{2}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1-\cos x\cos 2x}{x^2}=\dfrac{5}{2}$ ។

ជ. $\lim\limits_{x\to 0}\dfrac{1-\cos(1-\cos x)}{x^4}$ រាងមិនកំណត់ $\dfrac{0}{0}$

$$=\lim_{x\to 0}\frac{1-\cos\left(2\sin^2\dfrac{x}{2}\right)}{x^4}=\lim_{x\to 0}\frac{2\sin^2\left(\sin^2\dfrac{x}{2}\right)}{x^4}$$

$$=2\lim_{x\to 0}\left[\frac{\sin\left(\sin^2\dfrac{x}{2}\right)}{\left(\sin^2\dfrac{x}{2}\right)}\right]^2\times\frac{\sin^4\dfrac{x}{2}}{\left(\dfrac{x}{2}\right)^4}\times\frac{1}{16}=2\times\frac{1}{16}=\frac{1}{8}$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1-\cos(1-\cos x)}{x^4}=\dfrac{1}{8}$ ។

ឈ. $\lim\limits_{x\to 1}(1-x^2)\tan\dfrac{\pi x}{2}$ តាង $x=1-u$ នោះ $x\to 1$ គេបាន $u\to 0$

$$=\lim_{u\to 0}\left[1-(1-u)^2\right]\tan\left(\frac{\pi}{2}-\frac{\pi u}{2}\right)=\lim_{u\to 0}\left[u(2-u)\right]\cot\frac{\pi u}{2}$$

$$=\lim_{u\to 0}\left[(2-u)\frac{\dfrac{\pi u}{2}}{\tan\dfrac{\pi u}{2}}\times\frac{2}{\pi}\right]=2\times\frac{2}{\pi}=\frac{4}{\pi}$$

ដូចនេះ $\lim\limits_{x\to 1}(1-x^2)\tan\dfrac{\pi x}{2}=\dfrac{4}{\pi}$ ។

ញ. $\lim\limits_{x\to 1}\dfrac{\tan\pi x}{1-x}$ តាង $x=1-u$ នោះ $x\to 1$ គេបាន $u\to 0$

$$=\lim_{u\to 0}\frac{\tan(\pi-\pi u)}{u}=-\lim_{u\to 0}\frac{\tan\pi u}{\pi u}\times\pi=-\pi$$

ដូចនេះ $\lim\limits_{x\to 1}\dfrac{\tan\pi x}{1-x}=-\pi$ ។

លំហាត់ទី២៧

គេមានអនុគមន៍ $y = f(x) = \dfrac{2-2\cos ax}{x^2}$ ដែល $a \in \mathbb{R}$ ។

កំណត់តម្លៃនៃ a ដើម្បីឲ្យ $\lim\limits_{x\to 0} f(x) = 100$ ។

ដំណោះស្រាយ

កំណត់តម្លៃនៃ a ដើម្បីឲ្យ $\lim\limits_{x\to 0} f(x) = 100$

គេមាន $f(x) = \dfrac{2-2\cos ax}{x^2} = \dfrac{4\sin^2\dfrac{ax}{2}}{x^2}$

គេបាន $\lim\limits_{x\to 0} f(x) = \lim\limits_{x\to 0} \dfrac{4\sin^2\dfrac{ax}{2}}{x^2} = 4\lim\limits_{x\to 0} \dfrac{\sin^2\dfrac{ax}{2}}{\left(\dfrac{ax}{2}\right)^2} \times \dfrac{a^2}{4} = a^2$

ដោយ $\lim\limits_{x\to 0} f(x) = 100$ នោះ $a^2 = 100$ ឬ $a = \pm 10$ ។

ដូចនេះ $a = -10$ ឬ $a = 10$ ។

លំហាត់ទី២៨

មានអនុគមន៍ f កំណត់ដោយ $f(x) = \dfrac{\tan x - \sin x}{x^n}$ ដែល $n \in \mathbb{N}$ ។

កំណត់គ្រប់ n ដែលធ្វើឲ្យ $\lim\limits_{x\to 0} f(x)$ ជាចំនួនពិត ។

ដំណោះស្រាយ

កំណត់គ្រប់ n ដែលធ្វើឲ្យ $\lim\limits_{x\to 0} f(x)$ ជាចំនួនពិត

យើងមាន $f(x) = \dfrac{\tan x - \sin x}{x^n}$ ដោយ $\tan x = \dfrac{\sin x}{\cos x}$

គេបាន $f(x)=\dfrac{\dfrac{\sin x}{\cos x}-\sin x}{x^n}=\dfrac{\sin x(1-\cos x)}{x^n\cos x}=\dfrac{\sin x(1-\cos^2 x)}{x^n\cos x(1+\cos x)}$

$$=\frac{\sin^3 x}{x^n\cos x(1+\cos x)}=\frac{\sin^3 x}{x^n}\times\frac{1}{\cos x(1+\cos x)}$$

នោះ $\lim\limits_{x\to0}f(x)=\lim\limits_{x\to0}\dfrac{\sin^3 x}{x^n}\times\lim\limits_{x\to0}\dfrac{1}{\cos x(1+\cos x)}$

ដើម្បីឲ្យ $\lim\limits_{x\to0}f(x)$ ជាចំនួនពិតលុះត្រាតែ $\lim\limits_{x\to0}\dfrac{\sin^3 x}{x^n}$ ជាចំនួនពិតពោលគឺគេត្រូវឲ្យ $n\le3$ ហើយដោយ $n\in\mathbb{N}$ នោះ $n=1,2,3$ ។

.ចំពោះ $n=1$ ឬ $n=2$ គេបាន $\lim\limits_{x\to0}f(x)=0$ ។

.ចំពោះ $n=3$ គេបាន $\lim\limits_{x\to0}f(x)=\dfrac{1}{2}$ ។

លំហាត់ទី២៩

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}$ ខ. $\lim\limits_{x\to1}\dfrac{\sin\pi x}{x-1}$

គ. $\lim\limits_{x\to0}\left[\dfrac{1}{x^2}\left(\dfrac{2}{\cos x}+\cos x-3\right)\right]$ ឃ. $\lim\limits_{x\to1}\dfrac{1-\sin\dfrac{\pi x}{2}}{(1-x)^2}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}$

តាង $x=\dfrac{\pi}{2}-u$ ហើយកាលណា $x\to\dfrac{\pi}{2}$ នោះ $u\to0$

គេបាន $\lim_{x\to\frac{\pi}{2}}\frac{\pi-2x}{\cos x}=\lim_{u\to 0}\frac{\pi-2\left(\frac{\pi}{2}-u\right)}{\cos\left(\frac{\pi}{2}-u\right)}=\lim_{u\to 0}\frac{2u}{\sin u}=2$ ។

ខ. $\lim_{x\to 1}\frac{\sin\pi x}{x-1}$ តាង $x=1-u$ ហើយកាលណា $x\to 1$ នោះ $u\to 0$

គេបាន $\lim_{x\to 1}\frac{\sin\pi x}{x-1}=\lim_{u\to 0}\frac{\sin(\pi-\pi u)}{-u}=-\lim_{u\to 0}\frac{\sin\pi u}{\pi u}\times\pi=-\pi$ ។

គ. $\lim_{x\to 0}\left[\frac{1}{x^2}(\frac{2}{\cos x}+\cos x-3)\right]=\lim_{x\to 0}\frac{2-3\cos x+\cos^2 x}{x^2\cos x}$

$$=\lim_{x\to 0}\frac{(1-\cos x)(2-\cos x)}{x^2\cos x}$$

$$=\lim_{x\to 0}\frac{\sin^2 x}{x^2}\times\frac{2-\cos x}{\cos x(1+\cos x)}=\frac{1}{2}$$

ដូចនេះ $\lim_{x\to 0}\left[\frac{1}{x^2}(\frac{2}{\cos x}+\cos x-3)\right]=\frac{1}{2}$

ឃ. $\lim_{x\to 1}\frac{1-\sin\frac{\pi x}{2}}{(1-x)^2}$ តាង $z=1-x$ នាំឲ្យ $x=1-z$

កាលណា $x\to 1$ នោះ $z\to 0$

$$=\lim_{z\to 0}\frac{1-\sin(\frac{\pi}{2}-\frac{\pi z}{2})}{z^2}=\lim_{z\to 0}\frac{1-\cos\frac{\pi z}{2}}{z^2}$$

$$=\lim_{z\to 0}\frac{2\sin^2\frac{\pi z}{4}}{z^2}=2\lim_{z\to 0}\frac{\sin^2\frac{\pi z}{4}}{(\frac{\pi z}{4})^2}.\frac{\pi^2}{16}=\frac{\pi^2}{8}$$

ដូចនេះ $\lim_{x\to 1}\frac{1-\sin\frac{\pi x}{2}}{(1-x)^2}=\frac{\pi^2}{8}$ ។

លំហាត់ទី៣០

ចូរគណនាលីមីតខាងក្រោម៖

ក) $\lim\limits_{x\to0}\dfrac{\sin^2 x-\sin^2 3x}{1-\cos 4x}$

ខ) $\lim\limits_{x\to0}\dfrac{\cos x-\cos 3x}{1-\cos 2x}$

គ) $\lim\limits_{x\to0}\dfrac{x^2-\sin^2 x}{x^2-x\sin x}$

ឃ) $\lim\limits_{x\to0}\dfrac{1-2\cos 2x+\cos^2 2x}{x^3\sin 2x}$

ង) $\lim\limits_{x\to0}\dfrac{\tan 2x-\sin 2x}{x(1-\cos 4x)}$

ចា) $\lim\limits_{x\to0}\dfrac{3\sin 2x-\sin 6x}{x^3+\sin^3 x}$

ឆ) $\lim\limits_{x\to0}\dfrac{2-\cos 2x-\cos 4x}{1-\cos^4 5x}$

ជ) $\lim\limits_{x\to0}\dfrac{\sin^3(2x^2)}{(\tan x-\sin x)^2}$

ឈ) $\lim\limits_{x\to0}\dfrac{1-\cos^4(2x^3)}{(3\sin x-\sin 3x)^2}$

ញ) $\lim\limits_{x\to0}\dfrac{1-\cos^3 2x}{1-\cos^4 3x}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក) $$\lim_{x\to0}\frac{\sin^2 x-\sin^2 3x}{1-\cos 4x}=\lim_{x\to0}\frac{\sin^2 x-\sin^2 3x}{2\sin^2 2x}=\frac{1}{2}\lim_{x\to0}\frac{\dfrac{\sin^2 x-\sin^2 3x}{x^2}}{\dfrac{\sin^2 2x}{x^2}}$$

$$=\frac{1}{2}\lim_{x\to0}\frac{\left(\dfrac{\sin x}{x}\right)^2-\left(\dfrac{\sin 3x}{3x}\times3\right)^2}{\left(\dfrac{\sin 2x}{2x}\times2\right)^2}=\frac{1}{2}\times\frac{1-9}{4}=-1$$

ដូចនេះ $\lim\limits_{x\to0}\dfrac{\sin^2 x-\sin^2 3x}{1-\cos 4x}=-1$ ។

ខ) $$\lim_{x\to0}\frac{\cos x-\cos 3x}{1-\cos 2x}=\lim_{x\to0}\frac{\left(1-2\sin^2\dfrac{x}{2}\right)-\left(1-2\sin^2\dfrac{3x}{2}\right)}{2\sin^2 x}$$

$$= \lim_{x\to 0}\frac{-2\sin^2\frac{x}{2}+2\sin^2\frac{3x}{2}}{2\sin^2 x} = \lim_{x\to 0}\frac{-\sin^2\frac{x}{2}+\sin^2\frac{3x}{2}}{\sin^2 x}$$

$$= \lim_{x\to 0}\frac{\dfrac{-\sin^2\frac{x}{2}+\sin^2\frac{3x}{2}}{x^2}}{\dfrac{\sin^2 x}{x^2}} = \lim_{x\to 0}\frac{-\left(\dfrac{\sin\frac{x}{2}}{\frac{x}{2}}\times\frac{1}{2}\right)+\left(\dfrac{\sin\frac{3x}{2}}{\frac{3x}{2}}\times\frac{3}{2}\right)}{\left(\dfrac{\sin x}{x}\right)^2} = -\frac{1}{4}+\frac{9}{4} = 2 \text{ ។}$$

ដូចនេះ: $\lim_{x\to 0}\frac{\cos x-\cos 3x}{1-\cos 2x} = 2$ ។

គ) $\lim_{x\to 0}\frac{x^2-\sin^2 x}{x^2-x\sin x} = \lim_{x\to 0}\frac{(x-\sin x)(x+\sin x)}{x(x-\sin x)} = \lim_{x\to 0}\frac{x+\sin x}{x}$

$$= \lim_{x\to 0}\left(1+\frac{\sin x}{x}\right) = 1+1 = 2$$

ដូចនេះ: $\lim_{x\to 0}\frac{x^2-\sin^2 x}{x^2-x\sin x} = 2$ ។

ឃ) $\lim_{x\to 0}\frac{1-2\cos 2x+\cos^2 2x}{x^3\sin 2x} = \lim_{x\to 0}\frac{(1-\cos 2x)^2}{x^3\sin 2x} = \lim_{x\to 0}\frac{4\sin^4 x}{2x^3\sin x\cos x}$

$$= 2\lim_{x\to 0}\frac{\sin^3 x}{x^3\cos x} = 2\lim_{x\to 0}\left[\left(\frac{\sin x}{x}\right)^3\frac{1}{\cos x}\right] = 2 \text{ ។}$$

ដូចនេះ: $\lim_{x\to 0}\frac{1-2\cos 2x+\cos^2 2x}{x^3\sin 2x} = 2$ ។

ង) $\lim_{x\to 0}\frac{\tan 2x-\sin 2x}{x(1-\cos 4x)} = \lim_{x\to 0}\frac{\frac{\sin 2x}{\cos 2x}-\sin 2x}{2x\sin^2 2x} = \lim_{x\to 0}\frac{\sin 2x(1-\cos 2x)}{2x\sin^2 2x\cos 2x}$

$$= \lim_{x\to 0}\frac{2\sin^2 x}{2x\sin 2x\cos 2x} = \lim_{x\to 0}\frac{\sin^2 x}{2x\sin x\cos x\cos 2x}$$

$$= \lim_{x\to 0}\frac{\sin x}{x}\times\frac{1}{2\cos x\cos 2x} = \frac{1}{2}$$

ដូចនេះ: $\lim\limits_{x\to 0}\frac{\tan 2x-\sin 2x}{x\left(1-\cos 4x\right)}=\frac{1}{2}$ ។

ប) $\lim\limits_{x\to 0}\frac{3\sin 2x-\sin 6x}{x^3+\sin^3 x}=\lim\limits_{x\to 0}\frac{3\sin 2x-\left(3\sin 2x-4\sin^3 2x\right)}{x^3+\sin^3 x}$

$$=\lim_{x\to 0}\frac{4\sin^3 2x}{x^3+\sin^3 x}=4\lim_{x\to 0}\frac{\frac{\sin^3 2x}{x^3}}{\frac{x^3+\sin^3 x}{x^3}}=4\lim_{x\to 0}\frac{\left(\frac{\sin 2x}{2x}\times 2\right)^3}{1+\left(\frac{\sin x}{x}\right)^3}=\frac{4\times 8}{2}=16$$

ដូចនេះ: $\lim\limits_{x\to 0}\frac{3\sin 2x-\sin 6x}{x^3+\sin^3 x}=16$ ។

ផ) $\lim\limits_{x\to 0}\frac{2-\cos 2x-\cos 4x}{1-\cos^4 5x}=\lim\limits_{x\to 0}\frac{\left(1-\cos 2x\right)+\left(1-\cos 4x\right)}{\left(1-\cos^2 5x\right)\left(1+\cos^2 5x\right)}$

$$=\lim_{x\to 0}\frac{2\sin^2 x+2\sin^2 2x}{\sin^2 5x\left(1+\cos^2 5x\right)}=2\lim_{x\to 0}\frac{\frac{\sin^2 x+\sin^2 2x}{x^2}}{\frac{\sin^2 5x}{x^2}\left(1+\cos^2 5x\right)}$$

$$=2\lim_{x\to 0}\frac{\left(\frac{\sin x}{x}\right)^2+\left(\frac{\sin 2x}{2x}\times 2\right)^2}{\left(\frac{\sin 5x}{5x}\times 5\right)^2\left(1+\cos^2 5x\right)}=2\times\frac{1+4}{25\times 2}=\frac{1}{5}$$ ។

ដូចនេះ: $\lim\limits_{x\to 0}\frac{2-\cos 2x-\cos 4x}{1-\cos^4 5x}=\frac{1}{5}$ ។

ព) $\lim\limits_{x\to 0}\frac{\sin^3(2x^2)}{(\tan x-\sin x)^2}=\lim\limits_{x\to 0}\frac{\sin^3\left(2x^2\right)}{\left(\tan x-\cos x\tan x\right)^2}=\lim\limits_{x\to 0}\frac{\sin^3\left(2x^2\right)}{\left(1-\cos x\right)^2\tan^2 x}$

$$=\lim_{x\to 0}\frac{\sin^3(2x^2)}{4\sin^4\frac{x}{2}\tan^2 x}=\frac{1}{4}\lim_{x\to 0}\frac{\left[\frac{\sin(2x^2)}{2x^2}\times 2\right]^3}{\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\times\frac{1}{2}\right)^4\left(\frac{\tan x}{x}\right)^2}=\frac{1}{4}\times\frac{2^3}{\frac{1}{16}}=32$$

ដូចនេះ $\lim_{x\to0}\dfrac{\sin^3(2x^2)}{(\tan x-\sin x)^2}=32$ ។

ឈ) $\lim_{x\to0}\dfrac{1-\cos^4(2x^3)}{(3\sin x-\sin 3x)^2}=\lim_{x\to0}\dfrac{\left[1-\cos^2(2x^3)\right]\left[1+\cos^2(2x^3)\right]}{\left[3\sin x-\left(3\sin x-4\sin^3 x\right)\right]^2}$

$$=\lim_{x\to0}\frac{\sin^2\left(2x^3\right)\left[1+\cos^2\left(2x^3\right)\right]}{16\sin^6 x}$$

$$=\frac{1}{16}\lim_{x\to0}\left[\frac{\sin\left(2x^3\right)}{2x^3}\times2\right]^2\left(\frac{x}{\sin x}\right)^6\left[1+\cos^2\left(2x^3\right)\right]=\frac{1}{16}\times4\times2=\frac{1}{2}$$

ដូចនេះ $\lim_{x\to0}\dfrac{1-\cos^4(2x^3)}{(3\sin x-\sin 3x)^2}=\dfrac{1}{2}$ ។

ញ) $\lim_{x\to0}\dfrac{1-\cos^3 2x}{1-\cos^4 3x}=\lim_{x\to0}\dfrac{\left(1-\cos 2x\right)\left(1+\cos 2x+\cos^2 2x\right)}{\left(1-\cos^2 3x\right)\left(1+\cos^2 3x\right)}$

$$=\lim_{x\to0}\frac{2\sin^2 x\left(1+\cos 2x+\cos^2 2x\right)}{\sin^2 3x\left(1+\cos^2 3x\right)}$$

$$=2\lim_{x\to0}\frac{\left(\dfrac{\sin x}{x}\right)^2}{\left(\dfrac{\sin 3x}{3x}\times3\right)}\frac{1+\cos 2x+\cos^2 2x}{1+\cos^2 3x}=2\times\frac{1}{9}\times\frac{3}{2}=\frac{1}{3}$$

ដូចនេះ $\lim_{x\to0}\dfrac{1-\cos^3 2x}{1-\cos^4 3x}=\dfrac{1}{3}$ ។

លំហាត់ទី៣១

ចូរគណនាលីមីតខាងក្រោម៖

ក) $\lim_{x\to0}\dfrac{1-\cos 2x\cos 6x}{\sin^2 5x}$

ខ) $\lim_{x\to0}\dfrac{1-\cos 4x}{1-\cos 6x}$

គ) $\lim_{x\to0}\dfrac{1-\cos^2 6x}{1-\cos^3 2x}$

ឃ) $\lim_{x\to0}\dfrac{1-\cos^2 2x\ \cos 4x}{x^2}$

ង) $\lim\limits_{x\to 0}\dfrac{\cos^2 2x-\cos 6x}{3\sin^2 x+\sin^2 2x}$

ច) $\lim\limits_{x\to 0}\dfrac{1-\sqrt{\cos^3 4x}}{3x^2}$

ឆ) $\lim\limits_{x\to 0}\dfrac{\cos 4x-\sqrt{\cos 2x}}{x^2}$

ជ) $\lim\limits_{x\to 0}\dfrac{1-\sqrt[3]{\cos 3x}}{x^2}$

ឈ) $\lim\limits_{x\to 0}\dfrac{\cos 2x-\sqrt[3]{\cos 4x}}{x^2}$

ញ) $\lim\limits_{x\to 0}\dfrac{1-\cos 2x\sqrt{\cos 4x}}{x^2}$

<u>ដំណោះស្រាយ</u>

គណនាលីមីតខាងក្រោម៖

ក) $\lim\limits_{x\to 0}\dfrac{1-\cos 2x\cos 6x}{\sin^2 5x}=\lim\limits_{x\to 0}\dfrac{(1-\cos 2x)+\cos 2x(1-\cos 6x)}{\sin^2 5x}$

$$=\lim_{x\to 0}\frac{2\sin^2 x+2\cos 2x\sin^2 3x}{\sin^2 5x}=2\lim_{x\to 0}\frac{\dfrac{\sin^2 x+\cos 2x\sin^2 3x}{x^2}}{\dfrac{\sin^2 5x}{x^2}}$$

$$=2\lim_{x\to 0}\frac{\left(\dfrac{\sin x}{x}\right)^2+\cos 2x\left(\dfrac{\sin 3x}{3x}\times 3\right)^2}{\left(\dfrac{\sin 5x}{5x}\times 5\right)^2}=2\times\frac{1+9}{25}=\frac{4}{5}$$

ដូចនេះ: $\lim\limits_{x\to 0}\dfrac{1-\cos 2x\cos 6x}{\sin^2 5x}=\dfrac{4}{5}$ ។

ខ) $\lim\limits_{x\to 0}\dfrac{1-\cos 4x}{1-\cos 6x}=\lim\limits_{x\to 0}\dfrac{2\sin^2 2x}{2\sin^2 3x}=\lim\limits_{x\to 0}\dfrac{\sin^2 2x}{\sin^2 3x}=\lim\limits_{x\to 0}\dfrac{\left(\dfrac{\sin 2x}{2x}\times 2\right)^2}{\left(\dfrac{\sin 3x}{3x}\times 3\right)^2}=\dfrac{4}{9}$

ដូចនេះ: $\lim\limits_{x\to 0}\dfrac{1-\cos 4x}{1-\cos 6x}=\dfrac{4}{9}$ ។

គ) $\lim\limits_{x\to 0}\dfrac{1-\cos^2 6x}{1-\cos^3 2x}=\lim\limits_{x\to 0}\dfrac{\sin^2 6x}{(1-\cos 2x)(1+\cos 2x+\cos^2 2x)}$

$$=\lim_{x\to 0}\frac{\sin^2 6x}{2\sin^2 x\left(1+\cos 2x+\cos^2 2x\right)}$$

$$=\frac{1}{2}\lim_{x\to 0}\frac{\left(\frac{\sin 6x}{6x}\times 6\right)^2}{\left(\frac{\sin x}{x}\right)^2\left(1+\cos 2x+\cos^2 2x\right)}=\frac{1}{2}\times\frac{36}{3}=6$$

ដូចនេះ: $\lim_{x\to 0}\frac{1-\cos^2 6x}{1-\cos^3 2x}=6$ ។

ឃ) $\lim_{x\to 0}\frac{1-\cos^2 2x\ \cos 4x}{x^2}=\lim_{x\to 0}\frac{\left(1-\cos^2 2x\right)+\cos^2 2x\left(1-\cos 4x\right)}{x^2}$

$$=\lim_{x\to 0}\frac{\sin^2 2x+2\cos^2 2x\sin^2 2x}{x^2}=\lim_{x\to 0}\frac{\sin^2 2x\left(1+2\cos^2 2x\right)}{x^2}$$

$$=\lim_{x\to 0}\left(\frac{\sin 2x}{2x}\times 2\right)^2\left(1+2\cos^2 2x\right)=4\times 3=12$$

ដូចនេះ: $\lim_{x\to 0}\frac{1-\cos^2 2x\ \cos 4x}{x^2}=12$ ។

ង) $\lim_{x\to 0}\frac{\cos^2 2x-\cos 6x}{3\sin^2 x+\sin^2 2x}=\lim_{x\to 0}\frac{1-\sin^2 2x-(1-2\sin^2 3x)}{3\sin^2 x+\sin^2 2x}$

$$=\lim_{x\to 0}\frac{2\sin^2 3x-\sin^2 2x}{3\sin^2 x+\sin^2 2x}=\lim_{x\to 0}\frac{\frac{2\sin^2 3x-\sin^2 2x}{x^2}}{\frac{3\sin^2 x+\sin^2 2x}{x^2}}$$

$$=\lim_{x\to 0}\frac{2\left(\frac{\sin 3x}{3x}\times 3\right)^2-\left(\frac{\sin 2x}{2x}\times 2\right)^2}{3\left(\frac{\sin x}{x}\right)^2+\left(\frac{\sin 2x}{2x}\times 2\right)^2}=\frac{14}{7}=2$$

ដូចនេះ: $\lim_{x\to 0}\frac{\cos^2 2x-\cos 6x}{3\sin^2 x+\sin^2 2x}=2$ ។

ច) $\lim\limits_{x\to 0}\dfrac{1-\sqrt{\cos^3 4x}}{3x^2}=\lim\limits_{x\to 0}\dfrac{1-\cos^3 4x}{3x^2\left(1+\sqrt{\cos^3 4x}\right)}$

$$=\lim_{x\to 0}\frac{(1-\cos 4x)\left(1+\cos 4x+\cos^2 4x\right)}{3x^2\left(1+\sqrt{\cos^3 4x}\right)}$$

$$=\lim_{x\to 0}\frac{2\sin^2 2x\left(1+\cos 4x+\cos^2 4x\right)}{3x^2\left(1+\sqrt{\cos^3 4x}\right)}$$

$$=\frac{2}{3}\lim_{x\to 0}\left(\frac{\sin 2x}{2x}\times 2\right)^2\frac{1+\cos 4x+\cos^2 4x}{1+\sqrt{\cos^3 4x}}=\frac{2}{3}\times 4\times\frac{3}{2}=4$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{1-\sqrt{\cos^3 4x}}{3x^2}=4$ ។

ឆ) $\lim\limits_{x\to 0}\dfrac{\cos 4x-\sqrt{\cos 2x}}{x^2}=\lim\limits_{x\to 0}\dfrac{\left(1-\sqrt{\cos 2x}\right)-(1-\cos 4x)}{x^2}$

$$=\lim_{x\to 0}\frac{1-\sqrt{\cos 2x}}{x^2}-\lim_{x\to 0}\frac{1-\cos 4x}{x^2}$$

$$=\lim_{x\to 0}\frac{1-\cos 2x}{x^2\left(1+\sqrt{\cos 2x}\right)}-\lim_{x\to 0}\frac{2\sin^2 2x}{x^2}$$

$$=\lim_{x\to 0}\frac{\sin^2 x}{x^2}\cdot\frac{2}{1+\sqrt{\cos 2x}}-2\lim_{x\to 0}\left(\frac{\sin 2x}{2x}\times 2\right)^2$$

$$=1-8=-7$$

ដូចនេះ $\lim\limits_{x\to 0}\dfrac{\cos 4x-\sqrt{\cos 2x}}{x^2}=-7$ ។

ជ) $\lim\limits_{x\to 0}\dfrac{1-\sqrt[3]{\cos 3x}}{x^2}=\lim\limits_{x\to 0}\dfrac{1-\cos 3x}{x^2\left(1+\sqrt[3]{\cos 3x}+\sqrt[3]{\cos^2 3x}\right)}$

$$=\lim_{x\to 0}\frac{2\sin^2\dfrac{3x}{2}}{x^2\left(1+\sqrt[3]{\cos 3x}+\sqrt[3]{\cos^2 3x}\right)}$$

$$= 2\lim_{x\to 0}\left(\frac{\sin\frac{3x}{2}}{\frac{3x}{2}}\times\frac{3}{2}\right)^2 \frac{1}{\left(1+\sqrt[3]{\cos 3x}+\sqrt[3]{\cos^2 3x}\right)} = 2\times\frac{9}{4}\times\frac{1}{3}=\frac{3}{2}$$

ដូចនេះ: $\lim_{x\to 0}\frac{1-\sqrt[3]{\cos 3x}}{x^2}=\frac{3}{2}$ ។

ឈ) $\lim_{x\to 0}\frac{\cos 2x-\sqrt[3]{\cos 4x}}{x^2}=\lim_{x\to 0}\frac{\left(1-\sqrt[3]{\cos 4x}\right)-\left(1-\cos 2x\right)}{x^2}$

$$=\lim_{x\to 0}\frac{1-\cos 4x}{x^2(1+\sqrt[3]{\cos 4x}+\sqrt[3]{\cos^2 4x})}-\lim_{x\to 0}\frac{1-\cos 2x}{x^2}$$

$$=\lim_{x\to 0}\frac{2\sin^2 2x}{x^2\left(1+\sqrt[3]{\cos 4x}+\sqrt[3]{\cos^2 4x}\right)}-\lim_{x\to 0}\frac{2\sin^2 x}{x^2}$$

$$=2\lim_{x\to 0}\left(\frac{\sin 2x}{2x}\times 2\right)^2\frac{1}{\left(1+\sqrt[3]{\cos 4x}+\sqrt[3]{\cos^2 4x}\right)}-2\lim_{x\to 0}\left(\frac{\sin x}{x}\right)^2=\frac{8}{3}-2=\frac{2}{3}$$

ដូចនេះ: $\lim_{x\to 0}\frac{\cos 2x-\sqrt[3]{\cos 4x}}{x^2}=\frac{2}{3}$ ។

ញ) $\lim_{x\to 0}\frac{1-\cos 2x\sqrt{\cos 4x}}{x^2}=\lim_{x\to 0}\frac{\left(1-\cos 2x\right)+\cos 2x\left(1-\sqrt{\cos 4x}\right)}{x^2}$

$$=\lim_{x\to 0}\frac{1-\cos 2x}{x^2}+\lim_{x\to 0}\frac{\cos 2x\left(1-\sqrt{\cos 4x}\right)}{x^2}$$

$$=\lim_{x\to 0}\frac{2\sin^2 x}{x^2}+\lim_{x\to 0}\frac{2\cos 2x\sin^2 2x}{x^2\left(1+\sqrt{\cos 4x}\right)}$$

$$=2\lim_{x\to 0}\left(\frac{\sin x}{x}\right)^2+2\lim_{x\to 0}\left(\frac{\sin 2x}{2x}\times 2\right)^2\frac{\cos 2x}{1+\sqrt{\cos 4x}}$$

$$=2+2\times 4\times\frac{1}{2}=2+4=6$$

ដូចនេះ: $\lim_{x\to 0}\frac{1-\cos 2x\sqrt{\cos 4x}}{x^2}=6$ ។

លំហាត់ទី៣២

ចូរគណនាលីមីតខាងក្រោម៖

ក. $\lim_{x\to 0}\frac{1-\cos x+\sin x}{x}$

ខ. $\lim_{x\to 0}\frac{1-\cos x}{x^2}$

គ. $\lim_{x\to 0}\frac{x+\tan x}{x+\tan 3x}$

ឃ. $\lim_{x\to 0}\frac{\sin[\sin(\sin x)]}{x}$

ង. $\lim_{x\to 0}\frac{\sin x\sin 2x\sin 3x....\sin(nx)}{x^n}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim_{x\to 0}\frac{1-\cos x+\sin x}{x}=\lim_{x\to 0}\frac{1-\cos x}{x}+\lim_{x\to 0}\frac{\sin x}{x}=0+1=1$

ខ. $\lim_{x\to 0}\frac{1-\cos x}{x^2}=\lim_{x\to 0}\frac{2\sin^2\frac{x}{2}}{x^2}=\frac{1}{2}\lim_{x\to 0}\left(\frac{\sin\frac{x}{2}}{\frac{x}{2}}\right)^2=\frac{1}{2}\times 1^2=\frac{1}{2}$

គ. $\lim_{x\to 0}\frac{x+\tan x}{x+\tan 3x}=\lim_{x\to 0}\frac{1+\frac{\tan x}{x}}{1+\frac{\tan 3x}{3x}.3}=\frac{1+1}{1+3}=\frac{1}{2}$ ។

ឃ. $\lim_{x\to 0}\frac{\sin\left[\sin(\sin x)\right]}{x}=\lim_{x\to 0}\frac{\sin\left[\sin(\sin x)\right]}{\sin(\sin x)}.\frac{\sin(\sin x)}{\sin x}.\frac{\sin x}{x}=1$

ង. $\lim_{x\to 0}\frac{\sin x\sin 2x\sin 3x....\sin(nx)}{x^n}$

$$=\lim_{x\to 0}\frac{\sin x}{x}.2\frac{\sin 2x}{2x}.3\frac{\sin 3x}{3x}....n.\frac{\sin(nx)}{nx}=1\times 2\times 3\times....\times n=n!$$

ដូចនេះ $\lim_{x\to 0}\frac{\sin x\sin 2x\sin 3x....\sin(nx)}{x^n}=n!$ ។

លំហាត់ទី៣៣

ចូរគណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 1}\dfrac{1-\sin\dfrac{\pi x}{2}}{(1-x)^2}$

ខ. $\lim\limits_{x\to \frac{\pi}{2}}\dfrac{\cos x}{\pi^2-4x^2}$

គ. $\lim\limits_{x\to \frac{\pi}{4}}\dfrac{\sin x-\cos x}{\pi-4x}$

ឃ. $\lim\limits_{x\to \frac{\pi}{2}}\dfrac{\sqrt{2}-\sqrt{1+\sin x}}{\cos^2 x}$

ង. $\lim\limits_{x\to 1}\dfrac{x^3-1+\tan\pi x}{1-x^2}$

ច. $\lim\limits_{x\to 2}(4-x^2)\tan\dfrac{\pi x}{4}$

ឆ. $\lim\limits_{x\to \pi}(\pi-x)\tan\dfrac{x}{2}$

ជ. $\lim\limits_{x\to \frac{\pi}{4}}\dfrac{1-\tan x}{1-\sqrt{2}\sin x}$

ឈ. $\lim\limits_{x\to \frac{\pi}{3}}\dfrac{\pi-3x}{\sqrt{3}-2\sin x}$

ញ. $\lim\limits_{x\to \pi}\dfrac{\cos\dfrac{\pi x}{x+\pi}}{\pi-x}$

ដ. $\lim\limits_{x\to 2}\dfrac{2-x}{\sin\dfrac{2\pi}{x}}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to 1}\dfrac{1-\sin\dfrac{\pi x}{2}}{(1-x)^2}$ តាង $z=1-x$ នាំឲ្យ $x=1-z$ កាលណា $x\to 1$ នោះ $z\to 0$

$$=\lim_{z\to 0}\frac{1-\sin(\frac{\pi}{2}-\frac{\pi z}{2})}{z^2}=\lim_{z\to 0}\frac{1-\cos\frac{\pi z}{2}}{z^2}=\lim_{z\to 0}\frac{2\sin^2\frac{\pi z}{4}}{z^2}$$

$$=2\lim_{z\to 0}\frac{\sin^2\frac{\pi z}{4}}{(\frac{\pi z}{4})^2}\cdot\frac{\pi^2}{16}=\frac{\pi^2}{8}$$

ដូចនេះ $\lim_{x\to1}\dfrac{1-\sin\dfrac{\pi x}{2}}{(1-x)^2}=\dfrac{\pi^2}{8}$ ។

ខ. $\lim_{x\to\frac{\pi}{2}}\dfrac{\cos x}{\pi^2-4x^2}$

តាង $z=\dfrac{\pi}{2}-x$ នាំឲ្យ $x=\dfrac{\pi}{2}-z$ កាលណា $x\to\dfrac{\pi}{2}$ នោះ $z\to0$

$$=\lim_{z\to0}\frac{\cos(\frac{\pi}{2}-z)}{\pi^2-4(\frac{\pi}{2}-z)^2}=\lim_{z\to0}\frac{\sin z}{\pi^2-\pi^2+4\pi z-4z^2}=\lim_{z\to0}\frac{\sin z}{4\pi z-4z^2}$$

$$=\lim_{z\to0}\frac{\sin z}{z}.\frac{1}{4\pi-4z}=\frac{1}{4\pi}$$

ដូចនេះ $\lim_{x\to\frac{\pi}{2}}\dfrac{\cos x}{\pi^2-4x^2}=\dfrac{1}{4\pi}$ ។

គ. $\lim_{x\to\frac{\pi}{4}}\dfrac{\sin x-\cos x}{\pi-4x}$

តាង $z=\dfrac{\pi}{4}-x$ នាំឲ្យ $x=\dfrac{\pi}{4}-z$ កាលណា $x\to\dfrac{\pi}{4}$ នោះ $z\to0$

$$=\lim_{z\to0}\frac{\sin(\frac{\pi}{4}-z)-\cos(\frac{\pi}{4}-z)}{\pi-4(\frac{\pi}{4}-z)}$$

$$=\lim_{z\to0}\frac{(\frac{\sqrt2}{2}\cos z-\frac{\sqrt2}{2}\sin z)-(\frac{\sqrt2}{2}\cos z+\frac{\sqrt2}{2}\sin z)}{4z}$$

$$=\lim_{z\to0}\frac{-\sqrt2\sin z}{4z}=-\frac{\sqrt2}{4}\lim_{z\to0}\frac{\sin z}{z}=-\frac{\sqrt2}{4}$$

ដូចនេះ $\lim_{x\to\frac{\pi}{4}}\dfrac{\sin x-\cos x}{\pi-4x}=-\dfrac{\sqrt2}{4}$

ឃ. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\sqrt{2}-\sqrt{1+\sin x}}{\cos^2 x}$

តាង $z=\dfrac{\pi}{2}-x$ នាំឲ្យ $x=\dfrac{\pi}{2}-z$ កាលណា $x\to\dfrac{\pi}{2}$ នោះ $z\to 0$

$$=\lim_{z\to 0}\frac{\sqrt{2}-\sqrt{1+\sin(\frac{\pi}{2}-z)}}{\cos^2(\frac{\pi}{2}-z)}=\lim_{z\to 0}\frac{\sqrt{2}-\sqrt{1+\cos z}}{\sin^2 z}$$

$$=\lim_{z\to 0}\frac{2-1-\cos z}{\sin^2 z.(\sqrt{2}+\sqrt{1+\cos z})}=\lim_{z\to 0}\frac{1-\cos z}{\sin^2 z(\sqrt{2}+\sqrt{1+\cos z})}$$

$$=\lim_{z\to 0}\frac{2-1-\cos z}{\sin^2 z.(\sqrt{2}+\sqrt{1+\cos z})}=\lim_{z\to 0}\frac{1-\cos z}{\sin^2 z(\sqrt{2}+\sqrt{1+\cos z})}$$

$$=\lim_{z\to 0}\frac{2\sin^2\frac{z}{2}}{\sin^2 z.(\sqrt{2}+\sqrt{1+\cos z})}$$

$$=2\lim_{z\to 0}\frac{\sin^2\frac{z}{2}}{(\frac{z}{2})^2}.\frac{z^2}{\sin^2 z}.\frac{1}{4}.\frac{1}{\sqrt{2}+\sqrt{1+\cos z}}=2.\frac{1}{4}.\frac{1}{2\sqrt{2}}=\frac{\sqrt{2}}{8}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{2}}\dfrac{\sqrt{2}-\sqrt{1+\sin x}}{\cos^2 x}=\dfrac{\sqrt{2}}{8}$ ។

ង. $\lim\limits_{x\to 1}\dfrac{x^3-1+\tan\pi x}{1-x^2}$

តាង $z=1-x$ នាំឲ្យ $x=1-z$ កាលណា $x\to 1$ នោះ $z\to 0$

$$=\lim_{z\to 0}\frac{(1-z)^3-1+\tan(\pi-\pi z)}{1-(1-z)^2}$$

$$=\lim_{z\to 0}\frac{(1-z)^3-1+\tan(\pi-\pi z)}{1-(1-z)^2}=\lim_{z\to 0}\frac{1-3z+3z^2-z^3-1-\tan\pi z}{1-1+2z-z^2}$$

$$=\lim_{z\to0}\frac{-3z+3z^2-z^3-\tan\pi z}{2z-z^2}=\lim_{z\to0}\frac{z(-3+3z-z^2-\frac{\tan\pi z}{z})}{z(2-z)}=\frac{-3-\pi}{2}$$

ដូចនេះ $\lim_{x\to1}\frac{x^3-1+\tan\pi x}{1-x^2}=-\frac{3+\pi}{2}$ ។

ប. $\lim_{x\to2}(4-x^2)\tan\frac{\pi x}{4}$ តាង $z=2-x$ នោះ $x=2-z$ បើ $x\to2$ នោះ $z\to0$

$$=\lim_{z\to0}\left[4-(2-z)^2\right]\tan\frac{\pi}{4}(2-z)=\lim_{z\to0}(4z-z^2)\tan(\frac{\pi}{2}-\frac{\pi z}{4})$$

$$=\lim_{z\to0}(4-z)\frac{\frac{\pi z}{4}}{\tan\frac{\pi z}{4}}.\frac{4}{\pi}=\frac{16}{\pi}$$

ដូចនេះ $\lim_{x\to2}(4-x^2)\tan\frac{\pi x}{4}=\frac{16}{\pi}$ ។

ផ. $\lim_{x\to\pi}(\pi-x)\tan\frac{x}{2}$ តាង $z=\pi-x\Rightarrow x=\pi-z$ បើ $x\to\pi$ នោះ $z\to0$

$$=\lim_{z\to0}z\tan\frac{\pi-z}{2}=\lim_{z\to0}z\tan(\frac{\pi}{2}-\frac{z}{2})=\lim_{z\to0}z\cot\frac{z}{2}=2\lim_{z\to0}\frac{\frac{z}{2}}{\tan\frac{z}{2}}=2$$

ដូចនេះ $\lim_{x\to\pi}(\pi-x)\tan\frac{x}{2}=2$

ព. $\lim_{x\to\frac{\pi}{4}}\frac{1-\tan x}{1-\sqrt{2}\sin x}$ តាង $z=\frac{\pi}{4}-x\Rightarrow x=\frac{\pi}{4}-z$ បើ $x\to\frac{\pi}{4}$ នោះ $z\to0$

$$=\lim_{z\to0}\frac{1-\tan(\frac{\pi}{4}-z)}{1-\sqrt{2}\sin(\frac{\pi}{4}-z)}=\lim_{z\to0}\frac{1-\frac{1-\tan z}{1+\tan z}}{1-\sqrt{2}(\frac{\sqrt{2}}{2}\cos z-\frac{\sqrt{2}}{2}\sin z)}$$

$$=\lim_{z\to0}\frac{1-\tan(\frac{\pi}{4}-z)}{1-\sqrt{2}\sin(\frac{\pi}{4}-z)}$$

$$=\lim_{z\to 0}\frac{1-\dfrac{1-\tan z}{1+\tan z}}{1-\sqrt{2}(\dfrac{\sqrt{2}}{2}\cos z-\dfrac{\sqrt{2}}{2}\sin z)}=\lim_{z\to 0}\frac{2\tan z}{(1-\cos z+\sin z)(1+\tan z)}$$

$$=2\lim_{z\to 0}\frac{\dfrac{\tan z}{z}}{(\dfrac{1-\cos z}{z}+\dfrac{\sin z}{z})(1+\tan z)}=2$$

ដូចនេះ $\displaystyle\lim_{x\to\frac{\pi}{4}}\frac{1-\tan x}{1-\sqrt{2}\sin x}=2$ ។

ឈ. $\displaystyle\lim_{x\to\frac{\pi}{3}}\frac{\pi-3x}{\sqrt{3}-2\sin x}$ តាង $z=\dfrac{\pi}{3}-x\Rightarrow x=\dfrac{\pi}{3}-z$ បើ $x\to\dfrac{\pi}{3}$ នោះ $z\to 0$

$$=\lim_{z\to 0}\frac{\pi-3(\dfrac{\pi}{3}-z)}{\sqrt{3}-2\sin(\dfrac{\pi}{3}-z)}=\lim_{z\to 0}\frac{3z}{\sqrt{3}-2(\dfrac{\sqrt{3}}{2}\cos z-\dfrac{1}{2}\sin z)}$$

$$=\lim_{z\to 0}\frac{3z}{\sqrt{3}-\sqrt{3}\cos z-\sin z}=\lim_{z\to 0}\frac{3}{\sqrt{3}\dfrac{1-\cos z}{z}-\dfrac{\sin z}{z}}=\frac{3}{0-1}=-3$$

ដូចនេះ $\displaystyle\lim_{x\to\frac{\pi}{3}}\frac{\pi-3x}{\sqrt{3}-2\sin x}=-3$ ។

ញ. $\displaystyle\lim_{x\to\pi}\frac{\cos\dfrac{\pi x}{x+\pi}}{\pi-x}$ តាង $t=\dfrac{\pi x}{x+\pi}\Rightarrow x=\dfrac{\pi t}{\pi-t}$ បើ $x\to\pi\ \Rightarrow t\to\dfrac{\pi}{2}$

$$=\lim_{t\to\frac{\pi}{2}}\frac{\cos t}{\pi-\dfrac{\pi t}{\pi-t}}=\lim_{t\to\frac{\pi}{2}}\frac{(\pi-t)\cos t}{\pi(\pi-2t)}$$

តាង $u=\dfrac{\pi}{2}-t\Rightarrow t=\dfrac{\pi}{2}-u$ បើ $t\to\dfrac{\pi}{2}\Rightarrow u\to 0$

$$=\lim_{u\to 0}\frac{(\pi-\dfrac{\pi}{2}+u)\cos(\dfrac{\pi}{2}-u)}{\pi(\pi-\pi+2u)}=\lim_{u\to 0}\frac{\dfrac{\pi}{2}+u}{2\pi}.\frac{\sin u}{u}=\frac{1}{4}$$

ដូចនេះ $\lim\limits_{x\to\pi}\dfrac{\cos\dfrac{\pi x}{x+\pi}}{\pi-x}=\dfrac{1}{4}$ ។

ដ. $\lim\limits_{x\to 2}\dfrac{2-x}{\sin\dfrac{2\pi}{x}}$ តាង $z=\dfrac{2}{x}\Rightarrow x=\dfrac{2}{z}$ បើ $x\to 2$ នោះ $z\to 1$

$=\lim\limits_{z\to 1}\dfrac{2-\dfrac{2}{z}}{\sin\pi z}=2\lim\limits_{z\to 1}\dfrac{z-1}{z.\sin\pi z}$

តាង $z=1-u\Rightarrow u=1-z$ បើ $z\to 1$ នោះ $u\to 0$

$=2\lim\limits_{u\to 0}\dfrac{-u}{(1-u)\sin(\pi-\pi u)}=-2\lim\limits_{u\to 0}\dfrac{1}{1-u}.\dfrac{\pi u}{\sin\pi u}.\dfrac{1}{\pi}=-\dfrac{2}{\pi}$ ។

ដូចនេះ $\lim\limits_{x\to 2}\dfrac{2-x}{\sin\dfrac{2\pi}{x}}=-\dfrac{2}{\pi}$ ។

លំហាត់ទី៣៤

ចូរគណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\pi}\dfrac{1-\sin\dfrac{x}{2}}{(\pi-x)^2}$

ខ. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}$

គ. $\lim\limits_{x\to\frac{1}{2}}\dfrac{\cos(\pi x)}{2x-1}$

ឃ. $\lim\limits_{x\to\frac{\pi}{4}}\dfrac{(\pi-4x)\cos 2x}{1-\sin 2x}$

ង. $\lim\limits_{x\to\frac{\pi}{3}}\dfrac{\pi-3x}{\sqrt{3}-2\sin x}$

ច. $\lim\limits_{x\to\frac{\pi}{4}}\dfrac{2\cos x-\sqrt{2}}{\pi-4x}$

ឆ. $\lim\limits_{x\to\frac{\pi}{3}}\dfrac{\cos x+\sqrt{3}\sin x-2}{(\pi-3x)^2}$

ជ. $\lim\limits_{x\to\frac{\pi}{4}}\dfrac{2-\sqrt{2}(\cos x+\sin x)}{\cos^2 2x}$

ឈ. $\lim\limits_{x\to 1}(1-x^2)\tan\left(\dfrac{\pi x}{2}\right)$

ញ. $\lim\limits_{x\to\frac{\pi}{2}}\left[(\pi-2x)\tan x\right]$

<u>ដំណោះស្រាយ</u>

គណនាលីមីតខាងក្រោម៖

ក. $\lim\limits_{x\to\pi}\dfrac{1-\sin\dfrac{x}{2}}{(\pi-x)^2}$

តាង $u=\pi-x$ នោះ $x=\pi-u$ កាលណា $x\to\pi$ នោះ $u\to 0$

គេបាន $\lim\limits_{x\to\pi}\dfrac{1-\sin\dfrac{x}{2}}{(\pi-x)^2}=\lim\limits_{u\to 0}\dfrac{1-\sin\left(\dfrac{\pi}{2}-\dfrac{u}{2}\right)}{u^2}=\lim\limits_{u\to 0}\dfrac{1-\cos\dfrac{u}{2}}{u^2}$

$=\lim\limits_{u\to 0}\dfrac{2\sin^2\dfrac{u}{4}}{u^2}=2\lim\limits_{u\to 0}\left(\dfrac{\sin\dfrac{u}{4}}{\dfrac{u}{4}}\times\dfrac{1}{4}\right)^2=2\times\dfrac{1}{16}=\dfrac{1}{8}$

ដូចនេះ៖ $\lim\limits_{x\to\pi}\dfrac{1-\sin\dfrac{x}{2}}{(\pi-x)^2}=\dfrac{1}{8}$ ។

ខ. $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}$

តាង $u=\dfrac{\pi}{2}-x$ នោះ $x=\dfrac{\pi}{2}-u$ កាលណា $x\to\dfrac{\pi}{2}$ នោះ $u\to 0$

យើងបាន $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}=\lim\limits_{u\to 0}\dfrac{\pi-2\left(\dfrac{\pi}{2}-u\right)}{\cos(\dfrac{\pi}{2}-u)}=\lim\limits_{u\to 0}\dfrac{2u}{\sin u}=2$ ។

ដូចនេះ៖ $\lim\limits_{x\to\frac{\pi}{2}}\dfrac{\pi-2x}{\cos x}=2$ ។

គ. $\lim\limits_{x\to\frac{1}{2}}\dfrac{\cos(\pi x)}{2x-1}$

តាង $u=\frac{1}{2}-x$ នោះ $x=\frac{1}{2}-u$ កាលណា $x\to\frac{1}{2}$ នោះ $u\to 0$

យើងបាន $\lim_{x\to\frac{1}{2}}\frac{\cos(\pi x)}{2x-1}=\lim_{u\to 0}\frac{\cos\left(\frac{\pi}{2}-\pi u\right)}{2\left(\frac{1}{2}-u\right)-1}=\lim_{u\to 0}\frac{\sin(\pi u)}{-2u}$

$=-\frac{\pi}{2}\lim_{u\to 0}\frac{\sin(\pi u)}{\pi u}=-\frac{\pi}{2}$

ដូចនេះ $\lim_{x\to\frac{1}{2}}\frac{\cos(\pi x)}{2x-1}=-\frac{\pi}{2}$ ។

ឃ. $\lim_{x\to\frac{\pi}{4}}\frac{(\pi-4x)\cos 2x}{1-\sin 2x}$

តាង $u=\frac{\pi}{4}-x$ នោះ $x=\frac{\pi}{4}-u$ កាលណា $x\to\frac{\pi}{4}$ នោះ $u\to 0$

យើងបាន $\lim_{x\to\frac{\pi}{4}}\frac{(\pi-4x)\cos 2x}{1-\sin 2x}=\lim_{u\to 0}\frac{(\pi-\pi+4u)\cos\left(\frac{\pi}{2}-2u\right)}{1-\sin\left(\frac{\pi}{2}-2u\right)}$

$$=\lim_{u\to 0}\frac{4u\sin 2u}{1-\cos 2u}=\lim_{u\to 0}\frac{8u\sin u\cos u}{2\sin^2 u}$$

$$=4\lim_{u\to 0}\left(\frac{u}{\sin u}\times\cos u\right)=4$$

ដូចនេះ $\lim_{x\to\frac{\pi}{4}}\frac{(\pi-4x)\cos 2x}{1-\sin 2x}=4$ ។

ង. $\lim_{x\to\frac{\pi}{3}}\frac{\pi-3x}{\sqrt{3}-2\sin x}$

តាង $u=\frac{\pi}{3}-x$ នោះ $x=\frac{\pi}{3}-u$ កាលណា $x\to\frac{\pi}{3}$ នោះ $u\to 0$

យើងបាន $\lim\limits_{x\to\frac{\pi}{3}}\dfrac{\pi-3x}{\sqrt{3}-2\sin x}=\lim\limits_{u\to 0}\dfrac{\pi-3\left(\dfrac{\pi}{3}-u\right)}{\sqrt{3}-2\sin\left(\dfrac{\pi}{3}-u\right)}$

$$=\lim_{u\to 0}\frac{3u}{\sqrt{3}-\sqrt{3}\cos u+\sin u}$$

$$=\lim_{u\to 0}\frac{3}{\sqrt{3}\dfrac{1-\cos u}{u}+\dfrac{\sin u}{u}}=3$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{3}}\dfrac{\pi-3x}{\sqrt{3}-2\sin x}=3$

ប. $\lim\limits_{x\to\frac{\pi}{4}}\dfrac{2\cos x-\sqrt{2}}{\pi-4x}$

តាង $u=\dfrac{\pi}{4}-x$ នោះ $x=\dfrac{\pi}{4}-u$ កាលណា $x\to\dfrac{\pi}{4}$ នោះ $u\to 0$

យើងបាន $\lim\limits_{x\to\frac{\pi}{4}}\dfrac{2\cos x-\sqrt{2}}{\pi-4x}=\lim\limits_{u\to 0}\dfrac{2\cos\left(\dfrac{\pi}{4}-u\right)-\sqrt{2}}{\pi-4\left(\dfrac{\pi}{4}-u\right)}$

$$=\lim_{u\to 0}\frac{\sqrt{2}\cos u+\sqrt{2}\sin u-\sqrt{2}}{4u}$$

$$=\frac{\sqrt{2}}{4}\lim_{u\to 0}\left(\frac{\sin u}{u}-\frac{1-\cos u}{u}\right)=\frac{\sqrt{2}}{4}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{4}}\dfrac{2\cos x-\sqrt{2}}{\pi-4x}=\dfrac{\sqrt{2}}{4}$ ។

ឆ. $\lim\limits_{x\to\frac{\pi}{3}}\dfrac{\cos x+\sqrt{3}\sin x-2}{(\pi-3x)^2}$

តាង $u=\dfrac{\pi}{3}-x$ នោះ $x=\dfrac{\pi}{3}-u$ កាលណា $x\to\dfrac{\pi}{3}$ នោះ $u\to 0$

គេបាន $\lim\limits_{x\to\frac{\pi}{3}}\dfrac{\cos x+\sqrt{3}\sin x-2}{(\pi-3x)^2}=\lim\limits_{u\to 0}\dfrac{\cos\left(\dfrac{\pi}{3}-u\right)+\sqrt{3}\sin\left(\dfrac{\pi}{3}-u\right)-2}{\left(\pi-\pi+3u\right)^2}$

$$=\lim_{u\to 0}\frac{\frac{1}{2}\cos u+\frac{\sqrt{3}}{2}\sin u+\frac{3}{2}\cos u-\frac{\sqrt{3}}{2}\sin u-2}{9u^2}$$

$$=\lim_{u\to 0}\frac{2\cos u-2}{9u^2}=\lim_{u\to 0}\frac{-4\sin^2\frac{u}{2}}{9u^2}$$

$$=-\frac{4}{9}\lim_{u\to 0}\left(\frac{\sin\frac{u}{2}}{\frac{u}{2}}\times\frac{1}{2}\right)^2=-\frac{4}{9}\times\frac{1}{4}=-\frac{1}{9}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{3}}\dfrac{\cos x+\sqrt{3}\sin x-2}{(\pi-3x)^2}=-\dfrac{1}{9}$ ។

ជ. $\lim\limits_{x\to\frac{\pi}{4}}\dfrac{2-\sqrt{2}\left(\cos x+\sin x\right)}{\cos^2 2x}$

តាង $u=\dfrac{\pi}{4}-x$ នោះ $x=\dfrac{\pi}{4}-u$ កាលណា $x\to\dfrac{\pi}{4}$ នោះ $u\to 0$

គេបាន $\lim\limits_{x\to\frac{\pi}{4}}\dfrac{2-\sqrt{2}\left(\cos x+\sin x\right)}{\cos^2 2x}=\lim\limits_{u\to 0}\dfrac{2-\sqrt{2}\left[\cos(\frac{\pi}{4}-u)+\sin(\frac{\pi}{4}-u)\right]}{\cos^2\left(\dfrac{\pi}{2}-2u\right)}$

$$=\lim_{u\to 0}\frac{2-2\cos u}{\sin^2 2u}=\lim_{u\to 0}\frac{4\sin^2\frac{u}{2}}{\sin^2 2u}=4\lim_{u\to 0}\left[\left(\frac{\sin\frac{u}{2}}{\frac{u}{2}}\times\frac{1}{2}\right)^2\left(\frac{2u}{\sin 2u}\times\frac{1}{2}\right)^2\right]=\frac{1}{4}$$

ដូចនេះ $\lim\limits_{x\to\frac{\pi}{4}}\dfrac{2-\sqrt{2}\left(\cos x+\sin x\right)}{\cos^2 2x}=\dfrac{1}{4}$ ។

ឈ. $\lim_{x\to 1}(1-x^2)\tan\left(\frac{\pi x}{2}\right)$

តាង $u=1-x$ នោះ $x=1-u$ កាលណា $x\to 1$ នោះ $u\to 0$

យើងបាន $\lim_{x\to 1}(1-x^2)\tan\left(\frac{\pi x}{2}\right)=\lim_{u\to 0}\left[\left(1-(1-u)^2\right)\tan\left(\frac{\pi}{2}-\frac{\pi u}{2}\right)\right]$

$$=\lim_{u\to 0}\left[u(2-u)cot\frac{\pi u}{2}\right]$$

$$=\lim_{u\to 0}\left[\frac{\frac{\pi u}{2}}{\tan\frac{\pi u}{2}}(2-u)\times\frac{2}{\pi}\right]=\frac{4}{\pi}$$

ដូចនេះ $\lim_{x\to 1}(1-x^2)\tan\left(\frac{\pi x}{2}\right)=\frac{4}{\pi}$ ។

ញ. $\lim_{x\to\frac{\pi}{2}}\left[(\pi-2x)\tan x\right]$

តាង $u=\frac{\pi}{2}-x$ នោះ $x=\frac{\pi}{2}-u$ កាលណា $x\to\frac{\pi}{2}$ នោះ $u\to 0$

យើងបាន $\lim_{x\to\frac{\pi}{2}}\left[(\pi-2x)\tan x\right]=\lim_{u\to 0}\left[(\pi-\pi+2u)\tan\left(\frac{\pi}{2}-u\right)\right]$

$$=\lim_{u\to 0}\left[2u\cot u\right]=2\lim_{u\to 0}\left(\frac{u}{\tan u}\right)=2$$

ដូចនេះ $\lim_{x\to\frac{\pi}{2}}\left[(\pi-2x)\tan x\right]=2$ ។

លំហាត់ទី៣៥

ចូរគណនាលីមីតខាងក្រោម៖

1) $\lim_{x\to\infty}\frac{4x^3-3x^2+1}{2x^3+x+3}$

2) $\lim_{x\to\infty}\frac{(4x^2+1)(6x^3+x)}{(3x+1)(8x^4+5)}$

3) $\lim_{x\to\infty}\frac{4x^3-7x^2+x+3}{6x^3+x^2-5x+1}$

4) $\lim_{x\to\infty}\frac{x^{10}+(x+1)^{10}+\ldots+(x+10)^{10}}{x^{10}+10^{10}}$

5) $\lim\limits_{x\to+\infty}\dfrac{x^{100}+(x+1)^{100}+....+(x+100)^{100}}{x^{100}+100^{100}}$ 6) $\lim\limits_{x\to+\infty}\dfrac{\sqrt{4x^2+x+3}}{x}$

7) $\lim\limits_{x\to\infty}\dfrac{\sqrt[3]{8x^3+4x+1}+x+2}{x}$ 8) $\lim\limits_{x\to\infty}\dfrac{8x+1}{\sqrt[3]{x^3+4x}+\sqrt[3]{27x^3+9x+1}}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម៖

1) $\lim\limits_{x\to\infty}\dfrac{4x^3-3x^2+1}{2x^3+x+3}=\lim\limits_{x\to\infty}\dfrac{x^3(4-\frac{3}{x}+\frac{1}{x^3})}{x^3(2+\frac{1}{x^2}+\frac{3}{x^3})}$

$$=\lim_{x\to\infty}\dfrac{4-\frac{3}{x}+\frac{1}{x^3}}{2+\frac{1}{x^2}+\frac{3}{x^3}}=\dfrac{4}{2}=2$$

2) $\lim\limits_{x\to\infty}\dfrac{(4x^2+1)(6x^3+x)}{(3x+1)(8x^4+5)}=\lim\limits_{x\to\infty}\dfrac{x^2(4+\frac{1}{x^2})x^3(6+\frac{1}{x^2})}{x(3+\frac{1}{x})x^4(8+\frac{5}{x^4})}$

$$=\lim_{x\to\infty}\dfrac{(4+\frac{1}{x^2})(6+\frac{1}{x^2})}{(3+\frac{1}{x})(8+\frac{5}{x^4})}=\dfrac{4\times6}{3\times8}=1$$

3) $\lim\limits_{x\to\infty}\dfrac{4x^3-7x^2+x+3}{6x^3+x^2-5x+1}=\lim\limits_{x\to\infty}\dfrac{x^3(4-\frac{7}{x}+\frac{1}{x^2}+\frac{3}{x^3})}{x^3(6+\frac{1}{x}-\frac{5}{x^2}+\frac{1}{x^3})}$

$$=\lim_{x\to\infty}\dfrac{4-\frac{7}{x}+\frac{1}{x^2}+\frac{3}{x^3})}{6+\frac{1}{x}-\frac{5}{x^2}+\frac{1}{x^3}}=\dfrac{2}{3}$$

ដូចនេះ $\lim_{x\to\infty}\frac{4x^3-7x^2+x+3}{6x^3+x^2-5x+1}=\frac{2}{3}$ ។

4) $\lim_{x\to\infty}\frac{x^{10}+(x+1)^{10}+\ldots+(x+10)^{10}}{x^{10}+10^{10}}$

$$=\lim_{x\to\infty}\frac{x^{10}+x^{10}(1+\frac{1}{x})^{10}+\ldots+x^{10}(1+\frac{10}{x})^{10}}{x^{10}+10^{10}}$$

$$=\lim_{x\to\infty}\frac{x^{10}\left[1+(1+\frac{1}{x})^{10}+\ldots.+(1+\frac{10}{x})^{10}\right]}{x^{10}\left(1+\frac{10^{10}}{x^{10}}\right)}$$

$$=\lim_{x\to\infty}\frac{1+(1+\frac{1}{x})^{10}+\ldots.+(1+\frac{10}{x})^{10}}{1+\frac{10^{10}}{x^{10}}}=\frac{1+1+\ldots.+1}{1}=11$$

5) $\lim_{x\to+\infty}\frac{x^{100}+(x+1)^{100}+\ldots.+(x+100)^{100}}{x^{100}+100^{100}}$

$$=\lim_{x\to+\infty}\frac{x^{100}+x^{100}(1+\frac{1}{x})^{100}+\ldots.+x^{100}(1+\frac{100}{x})^{100}}{x^{100}+100^{100}}$$

$$=\lim_{x\to\infty}\frac{x^{100}\left[1+(1+\frac{1}{x})^{100}+\ldots.+(1+\frac{100}{x})^{100}\right]}{x^{100}\left(1+\frac{100^{100}}{x^{100}}\right)}$$

$$=\lim_{x\to\infty}\frac{1+(1+\frac{1}{x})^{100}+\ldots.+(1+\frac{100}{x})^{100}}{1+\frac{100^{100}}{x^{100}}}=101$$

ដូចនេះ $\lim_{x\to+\infty}\frac{x^{100}+(x+1)^{100}+\ldots.+(x+100)^{100}}{x^{100}+100^{100}}=101$ ។

$$6)\ \lim_{x\to+\infty}\frac{\sqrt{4x^2+x+3}}{x}=\lim_{x\to+\infty}\frac{\sqrt{x^2(4+\frac{1}{x}+\frac{3}{x^2})}}{x}$$

$$=\lim_{x\to+\infty}\frac{x\sqrt{4+\frac{1}{x}+\frac{3}{x^2}}}{x}$$

$$=\lim_{x\to+\infty}\sqrt{4+\frac{1}{x}+\frac{3}{x^2}}=\sqrt{4}=2$$

ដូចនេះ: $\lim_{x\to+\infty}\frac{\sqrt{4x^2+x+3}}{x}=2$ ។

$$7)\lim_{x\to\infty}\frac{\sqrt[3]{8x^3+4x+1}+x+2}{x}=\lim_{x\to\infty}\frac{x\sqrt[3]{8+\frac{4}{x^2}+\frac{1}{x^3}}+x+2}{x}$$

$$=\lim_{x\to\infty}\left(\sqrt[3]{8+\frac{4}{x^2}+\frac{1}{x^3}}+1+\frac{2}{x}\right)=2+1=3$$

$$8)\lim_{x\to\infty}\frac{8x+1}{\sqrt[3]{x^3+4x}+\sqrt[3]{27x^3+9x+1}}$$

$$=\lim_{x\to\infty}\frac{x\left(8+\frac{1}{x}\right)}{x\sqrt[3]{1+\frac{4}{x^2}}+x\sqrt[3]{27+\frac{9}{x^2}+\frac{1}{x^3}}}$$

$$=\lim_{x\to\infty}\frac{8+\frac{1}{x}}{\sqrt[3]{1+\frac{4}{x^2}}+\sqrt[3]{27+\frac{9}{x^2}+\frac{1}{x^3}}}=\frac{8}{1+3}=2$$

ដូច $\lim_{x\to\infty}\frac{8x+1}{\sqrt[3]{x^3+4x}+\sqrt[3]{27x^3+9x+1}}=2$ ។

www.mathtoday.wordpress.com

លំហាត់ទី៣៦

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to\infty}\dfrac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}$ ខ. $\lim\limits_{x\to+\infty}\dfrac{e^x-x}{2e^x+1}$

គ. $\lim\limits_{x\to+\infty}(\sqrt{x+\sqrt{x+\sqrt{x}}}-\sqrt{x})$ ឃ. $\lim\limits_{x\to+\infty}\ln(\dfrac{2x+3}{x+1})$

ង. $\lim\limits_{x\to+\infty}(\sqrt[4]{x^4+4x^3}+\sqrt[3]{x^3+3x^2}+\sqrt{x^2+2x}-3x)$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{x\to\infty}\dfrac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}$ រាងមិនកំណត់ $\dfrac{\infty}{\infty}$

$$=\lim_{x\to\infty}\frac{x\left(1-\frac{1}{x}\right)x\left(2+\frac{3}{x}\right)x\left(\frac{2}{x}-1\right)}{x^2\left(1+\frac{1}{x^2}\right)x\left(2+\frac{1}{x}\right)}=\lim_{x\to\infty}\frac{\left(1-\frac{1}{x}\right)\left(2+\frac{3}{x}\right)\left(\frac{2}{x}-1\right)}{\left(1+\frac{1}{x^2}\right)\left(2+\frac{1}{x}\right)}=\frac{-2}{2}=-1$$

ដូចនេះ $\lim\limits_{x\to\infty}\dfrac{(x-1)(2x+3)(2-x)}{(x^2+1)(2x+1)}=-1$ ។

ខ. $\lim\limits_{x\to+\infty}\dfrac{e^x-x}{2e^x+1}$ រាងមិនកំណត់ $\dfrac{\infty}{\infty}$

$$=\lim_{x\to+\infty}\frac{e^x\left(1-\frac{x}{e^x}\right)}{e^x\left(2+\frac{1}{e^x}\right)}=\lim_{x\to+\infty}\frac{1-xe^{-x}}{2+e^{-x}}=\frac{1}{2}$$ ព្រោះ $\lim\limits_{x\to+\infty}e^{-x}=0$ ។

គ. $\lim\limits_{x\to+\infty}(\sqrt{x+\sqrt{x+\sqrt{x}}}-\sqrt{x})=\dfrac{1}{2}$

ឃ. $\lim\limits_{x\to+\infty}\ln(\dfrac{2x+3}{x+1})=\ln 2$

ង. $\lim_{x\to+\infty}(\sqrt[4]{x^4+4x^3}+\sqrt[3]{x^3+3x^2}+\sqrt{x^2+2x}-3x)=3$ ។

លំហាត់ទី៣៧

ចូរគណនាលីមីត ៖

ក. $\lim_{x\to+\infty}(\sqrt{4x^2+x+2}-2\sqrt{x^2-x+3})$

ខ. $\lim_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})$

ដំណោះស្រាយ

គណនាលីមីត ៖

ក. $\lim_{x\to+\infty}(\sqrt{4x^2+x+2}-2\sqrt{x^2-x+3})$ មានរាងមិនកំណត់ $+\infty-\infty$

$$=\lim_{x\to+\infty}\frac{4x^2+x+2-4x^2+4x-12}{\sqrt{4x^2+x+2}+2\sqrt{x^2-x+3}}=\lim_{x\to+\infty}\frac{5x-10}{x\sqrt{4+\frac{1}{x}+\frac{2}{x^2}}+2x\sqrt{1-\frac{1}{x}+\frac{3}{x^2}}}$$

$$=\lim_{x\to+\infty}\frac{x\left(5-\frac{10}{x}\right)}{x\left(\sqrt{4+\frac{1}{x}+\frac{2}{x^2}}+2\sqrt{1-\frac{1}{x}+\frac{3}{x^2}}\right)}=\lim_{x\to+\infty}\frac{5-\frac{10}{x}}{\sqrt{4+\frac{1}{x}+\frac{2}{x^2}}+2\sqrt{1-\frac{1}{x}+\frac{3}{x^2}}}$$

ដូចនេះ $\lim_{x\to+\infty}(\sqrt{4x^2+x+2}-2\sqrt{x^2-x+3})=\frac{5}{4}$ ។

ខ. $\lim_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})$ មានរាងមិនកំណត់ $+\infty-\infty$

$$=\lim_{x\to+\infty}\frac{x^2+x+2-x^2+x-3}{\sqrt{x^2+x+2}+\sqrt{x^2-x+3}}=\lim_{x\to+\infty}\frac{2x-1}{\sqrt{x^2+x+2}+\sqrt{x^2-x+3}}$$

$$=\lim_{x\to+\infty}\frac{x\left(2-\frac{1}{x}\right)}{x\left(\sqrt{1+\frac{1}{x}+\frac{2}{x^2}}+\sqrt{1-\frac{1}{x}+\frac{3}{x^2}}\right)}=\lim_{x\to+\infty}\frac{2-\frac{1}{x}}{\sqrt{1+\frac{1}{x}+\frac{2}{x^2}}+\sqrt{1-\frac{1}{x}+\frac{3}{x^2}}}=1$$

ដូចនេះ $\lim_{x\to+\infty}(\sqrt{x^2+x+2}-\sqrt{x^2-x+3})=1$ ។

លំហាត់ទី៣៨

ចូរគណនាលីមីត $\lim\limits_{n\to+\infty}\dfrac{1.2+2.3+3.4+....+(n-1)n}{n^3}$

ដំណោះស្រាយ

គណនាលីមីត $\lim\limits_{n\to+\infty}\dfrac{1.2+2.3+3.4+....+(n-1)n}{n^3}$

តាង $S_n=1.2+2.3+3.4+...+(n-1)n=\sum\limits_{k=2}^{n}\left[(k-1)k\right]$

$$=\sum_{k=1}^{n}\left[(k-1)k\right]=\sum_{k=1}^{n}\left(k^2\right)-\sum_{k=1}^{n}(k)=\frac{n(n+1)(2n+1)}{6}-\frac{n(n+1)}{2}$$

$$=\frac{n(n+1)\left[(2n+1)-3\right]}{6}=\frac{n(n+1)(n-1)}{3}$$

យើងបាន $\lim\limits_{n\to+\infty}\dfrac{1.2+2.3+3.4+....+(n-1)n}{n^3}=\lim\limits_{n\to+\infty}\dfrac{n(n+1)(n-1)}{3n^3}$

$$=\frac{1}{3}\lim_{n\to+\infty}\left(\frac{n^2-1}{n^2}\right)$$

$$=\frac{1}{3}\lim_{n\to+\infty}\left(1-\frac{1}{n^2}\right)=\frac{1}{3}$$

ដូចនេះ $\lim\limits_{n\to+\infty}\dfrac{1.2+2.3+3.4+....+(n-1)n}{n^3}=\dfrac{1}{3}$ ។

លំហាត់ទី៣៩

គណនាលីមីតខាងក្រោម ៖

ក. $\lim\limits_{n\to+\infty}(1-\dfrac{1}{2^2})(1-\dfrac{1}{3^2})....(1-\dfrac{1}{n^2})$

ខ. $\lim\limits_{n\to+\infty}(\dfrac{n}{\sqrt{n^4+1}}+\dfrac{n}{\sqrt{n^4+2}}+....+\dfrac{n}{\sqrt{n^4+n}})$ ។

ដំណោះស្រាយ

គណនាលីមីត ក. $\lim\limits_{n\to+\infty}(1-\frac{1}{2^2})(1-\frac{1}{3^2})....(1-\frac{1}{n^2})$

យក $A=\lim\limits_{n\to+\infty}(1-\frac{1}{2^2})(1-\frac{1}{3^2})...(1-\frac{1}{n^2})=\lim\limits_{n\to+\infty}\prod\limits_{k=2}^{n}\left(1-\frac{1}{k^2}\right)$

$$=\lim_{n\to+\infty}\prod_{k=2}^{n}\frac{(k-1)(k+1)}{k^2}=\lim_{n\to+\infty}\prod_{k=2}^{n}\left(\frac{k-1}{k}\times\frac{k+1}{k}\right)$$

$$=\lim_{n\to+\infty}\left(\frac{1}{2}.\frac{2}{3}....\frac{n-1}{n}\right)\times\left(\frac{3}{2}.\frac{4}{3}....\frac{n+1}{n}\right)=\lim_{n\to+\infty}\left(\frac{1}{n}\times\frac{n+1}{2}\right)=\frac{1}{2}$$

ដូចនេះ $A=\lim\limits_{n\to+\infty}(1-\frac{1}{2^2})(1-\frac{1}{3^2})...(1-\frac{1}{n^2})=\frac{1}{2}$ ។

គណនាលីមីត ខ. $\lim\limits_{n\to+\infty}(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+....+\frac{n}{\sqrt{n^4+n}})$

យក $S_n=\sum\limits_{k=1}^{n}\left(\frac{n}{\sqrt{n^4+k}}\right)=\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+\frac{n}{\sqrt{n^4+3}}+....+\frac{n}{\sqrt{n^4+n}}$

ចំពោះគ្រប់ $k\in\mathbb{N}$, $k\le n$ និង $n\in\mathbb{N}$ គេមាន $n^4+1\le n^4+k\le n^4+n$

គេទាញ $\frac{n}{\sqrt{n^4+n}}\le\frac{n}{\sqrt{n^4+k}}\le\frac{n}{\sqrt{n^4+1}}$

គេបាន $\sum\limits_{k=1}^{n}\left(\frac{n}{\sqrt{n^4+n}}\right)\le\sum\limits_{k=1}^{n}\left(\frac{n}{\sqrt{n^4+k}}\right)\le\sum\limits_{k=1}^{n}\left(\frac{n}{\sqrt{n^4+1}}\right)$

$$\frac{n^2}{\sqrt{n^4+n}}\le S_n\le\frac{n^2}{\sqrt{n^4+1}}$$

យើងបាន $\lim\limits_{n\to+\infty}\frac{n^2}{\sqrt{n^4+n}}\le\lim\limits_{n\to+\infty}S_n\le\lim\limits_{n\to+\infty}\frac{n^2}{\sqrt{n^4+1}}$

$1\le\lim\limits_{n\to+\infty}S_n\le 1$ នោះ $\lim\limits_{n\to+\infty}S_n=1$ ។

ដូចនេះ $\lim\limits_{n\to+\infty}(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+....+\frac{n}{\sqrt{n^4+n}})=1$ ។

លំហាត់ទី៤០

ចំពោះគ្រប់ $n \in \mathbb{N}$ គេមាន

$$S_n = \frac{2}{1\times 3}+\frac{2}{3\times 5}+\dots+\frac{2}{(2n+1)(2n+3)} = \sum_{p=0}^{n}\frac{2}{(2p+1)(2p+3)}$$

ក.គណនា S_n ជាអនុគមន៍នៃ n ដោយប្រើ $\frac{2}{(2p+1)(2p+3)}$ ជាទម្រង់ $\frac{a}{2p+1}+\frac{b}{2p+3}$ ។

ខ.គណនា $\lim_{n\to+\infty} S_n$ ។

ដំណោះស្រាយ

ក.គណនា S_n ជាអនុគមន៍នៃ n

យើងមាន $\frac{2}{(2p+1)(2p+3)} = \frac{(2p+3)-(2p+1)}{(2p+1)(2p+3)} = \frac{1}{2p+1}-\frac{1}{2p+3}$

យើងបាន $S_n = \sum_{p=0}^{n}\left(\frac{1}{2p+1}-\frac{1}{2p+3}\right) = \frac{1}{1}-\frac{1}{2n+3} = \frac{2(n+1)}{2n+3}$

ខ.គណនា $\lim_{n\to+\infty} S_n$

យើងបាន $\lim_{n\to+\infty} S_n = \lim_{n\to+\infty}\left(1-\frac{1}{2n+3}\right) = 1$ ព្រោះ $\lim_{n\to+\infty}\frac{1}{2n+3} = 0$ ។

លំហាត់ទី៤១

ដោយប្រើសមភាព $\frac{k}{(k+1)!} = \frac{1}{k!}-\frac{1}{(k+1)!}$ ចូរគណនាផលបូក៖

$S_n = \frac{1}{2!}+\frac{2}{3!}+\frac{3}{4!}+\dots+\frac{n}{(n+1)!}$ រួចទាញរក $\lim_{n\to+\infty} S_n$ ។

ដំណោះស្រាយ

គណនាផលបូក S_n រួចទាញរក $\lim_{n\to+\infty} S_n$

គេមាន $S_n = \frac{1}{2!}+\frac{2}{3!}+\frac{3}{4!}+...+\frac{n}{(n+1)!}=\sum_{k=1}^{n}\left[\frac{k}{(k+1)!}\right]$

ដោយ $\frac{k}{(k+1)!}=\frac{1}{k!}-\frac{1}{(k+1)!}$ នោះគេបាន៖

$S_n=\sum_{k=1}^{n}\left[\frac{1}{k!}-\frac{1}{(k+1)!}\right]=1-\frac{1}{(n+1)!}$ ។

ដូចនេះ៖ $S_n=1-\frac{1}{(n+1)!}$ និង $\lim_{n\to+\infty}S_n=\lim_{n\to+\infty}\left[1-\frac{1}{(n+1)!}\right]=1$ ។

លំហាត់ទី៤២

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to+\infty}\frac{x+2\ln x}{1-2x+\ln x}$

ខ. $\lim_{x\to+\infty}\frac{2e^x+x-1}{e^x+1}$

គ. $\lim_{x\to+\infty}[x-\ln(2e^x+1)]$

ឃ. $\lim_{x\to+\infty}\frac{3-2\ln x}{1+3\ln x}$

ង. $\lim_{x\to+\infty}\frac{2x-\ln x}{x+\ln x}$

ច. $\lim_{x\to\infty}\frac{2e^x+x-1}{e^x+x}$

ដំណោះស្រាយ

គណនាលីមីតខាងក្រោម ៖

ក. $\lim_{x\to+\infty}\frac{x+2\ln x}{1-2x+\ln x}$ មានរាងមិនកំណត់ $\frac{\infty}{\infty}$

ចែកភាគយកនិងភាគបែងនិង x គេបាន $\lim_{x\to+\infty}\frac{1+\frac{2\ln x}{x}}{\frac{1}{x}-2+\frac{\ln x}{x}}=-\frac{1}{2}$

ព្រោះ៖ $\lim_{x\to+\infty}\frac{\ln x}{x}=0$ ។

ដូចនេះ៖ $\lim_{x\to+\infty}\frac{x+2\ln x}{1-2x+\ln x}=-\frac{1}{2}$ ។

ខ. $\lim\limits_{x\to+\infty}\dfrac{2e^x+x-1}{e^x+1}$ មានរាងមិនកំណត់ $\dfrac{\infty}{\infty}$

គេបាន $\lim\limits_{x\to+\infty}\dfrac{2e^x+x-1}{e^x+1}=\lim\limits_{x\to+\infty}\dfrac{e^x\left(2+\dfrac{x}{e^x}-\dfrac{1}{e^x}\right)}{e^x\left(1+\dfrac{1}{e^x}\right)}=\lim\limits_{x\to+\infty}\dfrac{2+xe^{-x}-e^{-x}}{1+e^{-x}}=2$

ដូចនេះ $\lim\limits_{x\to+\infty}\dfrac{2e^x+x-1}{e^x+1}=2$

គ. $\lim\limits_{x\to+\infty}[x-\ln(2e^x+1)]$ មានរាងមិនកំណត់ $+\infty-\infty$

គេបាន $\lim\limits_{x\to+\infty}[x-\ln(2e^x+1)]=\lim\limits_{x\to+\infty}\left[\ln\left(e^x\right)-\ln\left(2e^x+1\right)\right]=\lim\limits_{x\to+\infty}\ln\left(\dfrac{e^x}{2e^x+1}\right)$

$=\lim\limits_{x\to+\infty}\ln\left(\dfrac{1}{2+e^{-x}}\right)=\ln\left(\dfrac{1}{2}\right)=-\ln 2$

ដូចនេះ $\lim\limits_{x\to+\infty}[x-\ln(2e^x+1)]=-\ln 2$ ។

ឃ. $\lim\limits_{x\to+\infty}\dfrac{3-2\ln x}{1+3\ln x}=\lim\limits_{x\to+\infty}\dfrac{-2\ln x}{3\ln x}=-\dfrac{2}{3}$

ង. $\lim\limits_{x\to+\infty}\dfrac{2x-\ln x}{x+\ln x}=\lim\limits_{x\to+\infty}\dfrac{2x}{x}=2$

ច. $\lim\limits_{x\to\infty}\dfrac{2e^x+x-1}{e^x+x}=\left[\begin{array}{l}\lim\limits_{x\to-\infty}\dfrac{2e^x+x-1}{e^x+x}=\lim\limits_{x\to-\infty}\dfrac{x}{x}=1\\ \lim\limits_{x\to+\infty}\dfrac{2e^x+x-1}{e^x+x}=\lim\limits_{x\to+\infty}\dfrac{2e^x}{e^x}=2\end{array}\right.$

លំហាត់ទី៤៣

ចូរគណនាលីមីតនៃអនុគមន៍ខាងក្រោម ៖

ក. $\lim\limits_{x\to0}\dfrac{e^x-e^{-x}}{\sin x}$

ខ. $\lim\limits_{x\to0}\dfrac{e^x+x-1}{x}$

គ. $\lim\limits_{x\to0}\dfrac{e^{-x^2}-\cos 2x}{x^2}$

ឃ. $\lim\limits_{x\to0}\dfrac{e^{\sin x}-e^{\tan x}}{x}$

ង. $\lim_{x\to 0}\frac{e^{ax}-e^{bx}}{x}$

ច. $\lim_{x\to 0}\frac{e^{x}+e^{-x}-2}{x^2}$

ឆ. $\lim_{x\to 0}\frac{e^{x}+e^{2x}-2}{\sin x}$

ជ. $\lim_{x\to 0}\frac{(e^{x}-1)(e^{3x}-1)}{x^2}$

ឈ. $\lim_{x\to 0}\frac{e^{x\sin 2x}-\cos 2x}{\tan^2 x}$

ញ. $\lim_{x\to +\infty} x(e^{\frac{2}{x}}-1)$

ដំណោះស្រាយ

គណនាលីមីត ៖

ក. $\lim_{x\to 0}\frac{e^{x}-e^{-x}}{\sin x}=\lim_{x\to 0}\frac{e^{2x}-1}{e^{x}\sin x}=\lim_{x\to 0}\frac{e^{2x}-1}{2x}\times\frac{x}{\sin x}\times\frac{2}{e^{x}}=2$ ។

ខ. $\lim_{x\to 0}\frac{e^{x}+x-1}{x}=\lim_{x\to 0}\left(\frac{e^{x}-1}{x}+1\right)=1+1=2$ ។

គ. $\lim_{x\to 0}\frac{e^{-x^2}-\cos 2x}{x^2}=\lim_{x\to 0}\frac{e^{-x^2}-1+2\sin^2 x}{x^2}=\lim_{x\to 0}\left[-\frac{e^{-x^2}-1}{-x^2}+2\frac{\sin^2 x}{x^2}\right]=1$

ឃ. $\lim_{x\to 0}\frac{e^{\sin x}-e^{\tan x}}{x}=\lim_{x\to 0}\frac{\left(e^{\sin x}-1\right)-\left(e^{\tan x}-1\right)}{x}$

$=\lim_{x\to 0}\frac{e^{\sin x}-1}{\sin x}\cdot\frac{\sin x}{x}-\lim_{x\to 0}\frac{e^{\tan x}-1}{\tan x}\cdot\frac{\tan x}{x}=1-1=0$

ង. $\lim_{x\to 0}\frac{e^{ax}-e^{bx}}{x}=\lim_{x\to 0}\frac{\left(e^{ax}-1\right)-\left(e^{bx}-1\right)}{x}=\lim_{x\to 0}\frac{e^{ax}-1}{ax}\cdot a-\lim_{x\to 0}\frac{e^{bx}-1}{bx}\cdot b=a-b$

ច. $\lim_{x\to 0}\frac{e^{x}+e^{-x}-2}{x^2}=\lim_{x\to 0}\frac{e^{2x}-2e^{x}+1}{x^2e^{x}}=\lim_{x\to 0}\left[\left(\frac{e^{x}-1}{x}\right)^2\times\frac{1}{e^{x}}\right]=1$ ។

ឆ. $\lim_{x\to 0}\frac{e^{x}+e^{2x}-2}{\sin x}=\lim_{x\to 0}\frac{\left(e^{x}-1\right)+\left(e^{2x}-1\right)}{\sin x}=\lim_{x\to 0}\frac{\frac{e^{x}-1}{x}+2\cdot\frac{e^{2x}-1}{2x}}{\frac{\sin x}{x}}=3$

ជ. $\lim_{x\to 0}\frac{(e^{x}-1)(e^{3x}-1)}{x^2}=\lim_{x\to 0}\frac{e^{x}-1}{x}\times\lim_{x\to 0}\frac{e^{3x}-1}{3x}\cdot 3=3$ ។

ឈ. $\lim\limits_{x\to 0}\dfrac{e^{x\sin 2x}-\cos 2x}{\tan^2 x}=\lim\limits_{x\to 0}\dfrac{e^{x\sin 2x}-1+2\sin^2 x}{\tan^2 x}$

$$=\lim_{x\to 0}\frac{\dfrac{e^{x\sin 2x}-1}{x\sin 2x}\times\dfrac{\sin 2x}{2x}\times 2+2\dfrac{\sin^2 x}{x^2}}{\dfrac{\tan^2 x}{x^2}}=4$$

